ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

លេខ: ៦១០ "ឧ" ក្រ៧
ចុះថ្ងៃទី ១២-៨-២០២២
-សំណុំរឿងព្រហ្មទណ្ឌលេខ: ១៥៤
ចុះថ្ងៃទី ១២-០១-២០២២
-សំណុំរឿងស៊ើបសួរលេខ: ១២៨
ចុះថ្ងៃទី១២-១២-២០២២
-សំណុំរឿងជំនុំជម្រះលេខ: ១៣៥៣
ចុះថ្ងៃទី ១៣-៤-២០២២

តាចនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០២២ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក នៅសាលសវនាការទី៣ ដោយមានសមាសភាព:

ក្រុមប្រឹក្សាជំនុំជម្រះ

-លោកចៅក្រម [redacted] ជាប្រធានក្រុមប្រឹក្សា
-លោកចៅក្រម [redacted] ជាចៅក្រមប្រឹក្សា
-លោកស្រីចៅក្រម [redacted] ជាចៅក្រមប្រឹក្សា

តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះ លើសំណុំរឿងព្រហ្មទណ្ឌ លេខ ១៥៤ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ:

-ឈ្មោះ [redacted] **សីហា** ភេទប្រុស កើតថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៩៤ អាយុ២៨ឆ្នាំ ជនជាតិខ្មែរ មុខរបរ កម្មករសំណង់ មានទីកន្លែងកំណើតនៅ [redacted] ខេត្តពោធិ៍សាត់ សាសនាព្រះពុទ្ធ កំរិតវប្បធម៌ គ្មាន ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះជួលគ្មានលេខ ផ្លូវបេតុង ភូមិប៉ប្រកខាងជើង សង្កាត់កាកាប១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] **ចន្ថា** "ស" ម្តាយឈ្មោះ [redacted] **ផល្លា** "ស" ទោសពីមុន គ្មាន ជានីតិជន។

-ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ (ម១) តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣៤៣ "ប" ដ.ឃ.ដ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ ។

-មានមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ជាប់ចោទពីបទ **លួចមានស្ថានទម្ងន់ទោស (ឆក់ទូរស័ព្ទ)** ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ៣៤៤ ផ្លូវបេតុង ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

-ជនរងគ្រោះឈ្មោះ [redacted] **នីហ្គិច** ភេទស្រី អាយុ១២ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅសព្វថ្ងៃនៅផ្ទះលេខ៣៤៤ ផ្លូវបេតុង ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សេងលាង** ភេទស្រី អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ៣៤៤ ផ្លូវបេតុង ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

អត្ថហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ១៦ និង ៣០នាទី នៅចំណុចផ្ទះ៣៤៤ ផ្លូវបេតុង ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ ជនជាប់ចោទឈ្មោះ [redacted] **សីហា** ភេទប្រុស អាយុ២៨ឆ្នាំ បានជិះម៉ូតូមួយគ្រឿងក្នុងគោលបំណងធ្វើសកម្មភាពឆក់យក ទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ តាមដងផ្លូវ លុះដល់ចំណុចកើតហេតុ ក៏ជួបជនរងគ្រោះឈ្មោះ [redacted] **នីហ្គេច** ភេទស្រី **អាយុ១២ឆ្នាំ** កំពុងតែដើរកាន់ទូរស័ព្ទម៉ាក IPHONE 6 PLUS ពណ៌ស រូបគេបានឆក់ទូរស័ព្ទជនរងគ្រោះ ពេលនោះជនរងគ្រោះក៏បានស្រែកឆោឡោឡើងថាចោរៗ និងរត់តាមពីក្រោយម៉ូតូរបស់ជនជាប់ចោទ អ្នកជិតខាងបានដេញតាមបានបន្តិចជនជាប់ចោទ បានដួលម៉ូតូតាមដងផ្លូវ ក៏ឃាត់ខ្លួនជនត្រូវចោទប្រគល់ឱ្យសមត្ថកិច្ចប៉ុស្តិ៍នគរបាលអូរបែកក្អម ។

-**បានឃើញ** របាយការណ៍សំយោគលេខ ០១២ /**២២** រ.ប.ក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ លេខ **១៤៧ អ.ឃ.ញ** ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសន្និដ្ឋានស្តាពរលេខ **១០១៥ អ.ឃ.ញ** ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាដំណោះស្រាយ(បញ្ជូនសំណុំរឿងទៅជំនុំជម្រះ) លេខ **១៥១៨ "ប" ដ.ដ** ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

ឆាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted]សីហា បានឆ្លើយថា: កាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ១៦ និង ៣០នាទី ខ្លួនបានជិះម៉ាកសេ ១២៥ ពណ៌ខ្មៅ ពាក់ស្លាកលេខ កំពង់ធំ 1E-7201 ចេញពីម្តុំអាស៊ីអាគ្នេយ៍ ដល់ម្តុំផ្ទះរបស់ប្រជាពលរដ្ឋមានលក់ការ្ហេ នៅភូមិទ្រង់មាន់ សង្កាត់អូរបែកក្អម បានឃើញក្មេងស្រីម្នាក់ដើរកាន់ទូរស័ព្ទដៃ ភ្លាមនោះខ្លួនជិះម៉ូតូទៅអែបទន្ទឹមក្មេងស្រីនោះ រួចខ្លួនយកដៃស្តាំធ្វើសកម្មភាពឆក់យកទូរស័ព្ទពីដៃក្មេងស្រីនោះបានសម្រេច ហើយបន្តែមល្បឿនទៅមុខបណ្តាលឱ្យដួលម៉ូតូលើផ្លូវ ហើយត្រូវប្រជាពលរដ្ឋក្បែរនោះឃាត់ខ្លួនប្រគល់ឱ្យសមត្ថកិច្ច ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] **សេងណាង** បានឆ្លើយថា: នៅថ្ងៃកើតហេតុខ្លួនកំពុងនៅក្នុងផ្ទះ ហើយកូនស្រីខ្លួនឈ្មោះ [redacted] **នីហ្គិច** អាយុ១២ឆ្នាំ នៅលេងមុខផ្ទះកាន់ទូរស័ព្ទដៃ ម៉ាកអាយហ្វូន ៦ផ្លើស ពណ៌ស ស្រាប់តែកូនស្រីស្រែកចោរៗ ខ្លួនក៏ស្ទុះចេញពីក្នុងផ្ទះ ឃើញកូនស្រីខ្លួនរត់តាមពីក្រោយម៉ូតូនិងផ្លើលអ្នកជិតខាងរត់តាមក្រោយបណ្តាលឱ្យជនជាប់ចោទដួលម៉ូតូ ហើយក៏នាំគ្នាឃាត់ខ្លួនជនជាប់ចោទឱ្យសមត្ថកិច្ច ។ ទូរស័ព្ទខ្លួនបានទទួលវិញហើយ ខ្លួនមិនទាមទារសំណងជម្ងឺចិត្តទេ។

-តាមអំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] **នីហ្គិច** នៅសមត្ថកិច្ចបានឆ្លើយថា: នៅថ្ងៃកើតហេតុខ្លួនកាន់ទូរស័ព្ទដៃម៉ាក អាយហ្វូន៦ផ្លើស ពណ៌ស ដើរលេងនៅមុខផ្ទះ ស្រាប់តែមានមនុស្សប្រុសម្នាក់ជិះម៉ូតូមកឆក់យកទូរស័ព្ទដៃពីខ្លួន បានសម្រេច ហើយបើកម៉ូតូទៅមុខ ខ្លួនស្រែកថាចោៗ និងរត់តាមពីក្រោយ ពេលនោះបណ្តាលឱ្យដួលម៉ូតូ ហើយឪពុកខ្លួនរត់មកឃាត់ខ្លួនជននោះ ហើយបានយកទូរស័ព្ទប្រគល់ឱ្យខ្លួនវិញ។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ឆ្លងតាមការសាកសួរដេញដោលនាពេលសវនាការ ឃើញថា មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សីហា ពីបទ "លួចមានស្ថានទម្ងន់ទោស (ឆក់ទូរស័ព្ទ) ប្រព្រឹត្តនៅចំណុចមុខផ្ទះ៣៤៤ ផ្លូវបេតុង ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ

រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា: បន្ទាប់ពីបានសួរដេញដោលរួចមកឃើញថា កូនក្តីខ្លួនបានទទួលស្គាល់ថាពិតជាបានធ្វើសកម្មភាពធក់ទូរស័ព្ទរបស់ជនរងគ្រោះប្រាកដមែន ។ ក្នុងសកម្មភាពនេះកូនក្តីខ្លួនមិនបានប្រើអំពើហិង្សាទៅលើជនរងគ្រោះ នោះទេ ដូចនេះ សូមក្រុមប្រឹក្សាជំនុំជម្រះពិចារណាកែប្រែបទចោទពីបទ **លួចមានស្ថានទម្ងន់ទោស** មកជា បទ **លួច** វិញ និងសូមឱ្យតុលាការបន្ធូរបន្ថយទោសឱ្យកូនក្តីខ្លួនផង។

-ជនជាប់ចោទឈ្មោះ [redacted] **សីហា** បាននិយាយសំដីចុងក្រោយបង្អស់ថា: សុំឱ្យតុលាការបន្ធូរបន្ថយទោស ខ្លួនដឹងកំហុសហើយ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

សាលាដំបូងរាជធានីភ្នំពេញ

យល់ឃើញថា

១-នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ១៦ និង ០០ នាទី នៅចំណុចមុខផ្ទះ៣៤៤ ផ្លូវបេតុង ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ ជនជាប់ចោទឈ្មោះ [redacted] **សីហា** ភេទប្រុស អាយុ២៨ឆ្នាំ បានជិះម៉ូតូធ្វើសកម្មភាពធក់ទូរស័ព្ទដៃពីជនរងគ្រោះឈ្មោះ [redacted] **នីហ្គិច** តែត្រូវបានជនរងគ្រោះស្រែកថាចោរៗ ហើយត្រូវបានប្រជាពលរដ្ឋធ្វើការឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] **សីហា** ប្រគល់ឱ្យសមត្ថកិច្ច។

២-នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] **សីហា** បានឆ្លើយថា:កាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ១៦ និង ៣០នាទី ខ្លួនបានជិះម៉ាកសេ១២៥ ពណ៌ខ្មៅ ពាក់ស្លាកលេខ កំពង់ធំ 1E-7201 ចេញពីម្តុំអាស៊ីអាគ្នេយ៍ ដល់ចំណុចម្តុំផ្ទះរបស់ប្រជាពលរដ្ឋមានលក់កាហ្វេ នៅភូមិទ្រង់មាន់ បានឃើញក្មេងស្រីម្នាក់ដើរកាន់ទូរស័ព្ទដៃ ភ្លាមនោះខ្លួនជិះម៉ូតូទៅអែបទន្ទឹមក្មេងស្រីនោះ រួចខ្លួនយកដៃស្តាំធ្វើសកម្មភាពធក់យកទូរស័ព្ទពីដៃក្មេងស្រីនោះបានសម្រេច ហើយបន្តែមល្បឿនទៅមុខបណ្តាលឱ្យដួលម៉ូតូលើផ្លូវ ហើយត្រូវប្រជាពលរដ្ឋក្បែរនោះចាប់ខ្លួនប្រគល់ឱ្យសមត្ថកិច្ច។

៣-តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សេងលាង** បានឆ្លើយថា: នៅថ្ងៃកើតហេតុខ្លួនកំពុងនៅក្នុងផ្ទះហើយកូនស្រីខ្លួនឈ្មោះ [redacted] **នីហ្គិច** អាយុ១២ឆ្នាំ នៅលេងមុខផ្ទះកាន់ទូរស័ព្ទដៃ ម៉ាកអាយហ្វូន ៦ផ្លឹស ពណ៌ស ស្រាប់តែកូនស្រីស្រែកចោរៗ ខ្លួនក៏ស្ទុះចេញពីក្នុងផ្ទះ ឃើញកូនស្រីខ្លួនរត់តាមពីក្រោយម៉ូតូ និងផ្លើលអ្នកជិតខាងរត់តាមក្រោយដែរបណ្តាលឱ្យជនជាប់ចោទដួលម៉ូតូ ហើយក៏នាំគ្នាឃាត់ខ្លួនជនជាប់ចោទឱ្យសមត្ថកិច្ច ខ្លួនមិនទាមទារសំណងជម្ងឺចិត្តទេ ។

៤-តាមអំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] **នីហ្គិច** នៅសមត្ថកិច្ចបានឆ្លើយថា: នៅថ្ងៃកើតហេតុខ្លួនកាន់ទូរស័ព្ទដៃម៉ាក អាយហ្វូន ៦ផ្លើស ពណ៌ស ដើរលេងនៅមុខផ្ទះ ស្រាប់តែមានមនុស្សប្រុសម្នាក់ជិះម៉ូតូមក

ឆក់យកទូរស័ព្ទដៃពីខ្លួន បានសម្រេច ហើយបើកម៉ូតូទៅមុខ ខ្លួនស្រែកថាចោៗ និងរត់តាមពីក្រោយ ពេលនោះ បណ្តាលឲ្យដួលម៉ូតូ ហើយឌឹពុកខ្លួនរត់មកឃាត់ខ្លួនជនឆោះ ហើយបានយកទូរស័ព្ទប្រគល់ឲ្យខ្លួនវិញ ។

៥-តាមចម្លើយសារភាពរបស់ជនជាប់ចោទ ឈ្មោះ [redacted] **សីហា** ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] **សេងលាង** ,ចម្លើយជនរងគ្រោះឈ្មោះ [redacted] **នីហ្គិច** និងជារបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ សុទ្ធតែបញ្ជាក់យ៉ាងច្បាស់ថា ជនជាប់ចោទឈ្មោះ [redacted] **សីហា** ពិតជាបានជិះម៉ូតូធ្វើសកម្មភាព ឆក់ទូរស័ព្ទដៃ ពីជនរងគ្រោះ ដើម្បីយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនពិតប្រាកដមែន។

៦-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **សីហា** មានចេតនាទុច្ចរិត ដែលបានធ្វើសកម្មភាព ឆក់ទូរស័ព្ទដៃរបស់ជនរងគ្រោះ ដែលអំពើនេះស្តែងឲ្យឃើញ អំពីចេតនាប្រើហិង្សាទៅលើជនរងគ្រោះ ដើម្បីយកទ្រព្យជនរងគ្រោះ គឺជាបទល្មើសព្រហ្មទណ្ឌ ដែលច្បាប់បញ្ញត្តិថាជាបទ **លួចមានស្ថានទម្ងន់ទោស**។

៧-ជនជាប់ចោទឈ្មោះ [redacted] **សីហា** ក្នុងពេលប្រព្រឹត្ត និងក្រោយពេលប្រព្រឹត្តជននេះ មានសមត្ថភាពលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនចំពោះមុខច្បាប់ព្រហ្មទណ្ឌជាធរមាន។

៨-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **សីហា** បានបង្ហាញឲ្យឃើញថា គ្រប់សកម្មភាពមុន និងក្នុងពេលប្រព្រឹត្តក៏ដូចជាក្រោយពេលប្រព្រឹត្តបទល្មើស ជនជាប់ចោទរូបនេះ មានចេតនាទុច្ចរិត ដែលការប្រព្រឹត្តទាំងនេះធ្វើឲ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ បណ្តាលឲ្យប៉ះពាល់ដល់សន្តិសុខសង្គម សណ្តាប់ធ្នាប់សាធារណៈ ប៉ះពាល់ដល់នីតិានុកូលភាពសង្គម បំពានដល់នីតិានុកូលភាពសង្គម និងបំពានលើមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៩-មានភស្តុតាង និងមានពិរុទ្ធភាពដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **សីហា** ភេទប្រុស អាយុ៣២ឆ្នាំ ពីបទ **លួចមានស្ថានទម្ងន់ទោស (ឆក់ទូរស័ព្ទ)** ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ៣៤៤ ផ្លូវបេតុង ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

១០-ជនជាប់ចោទឈ្មោះ [redacted] **សីហា** ជាជនក្រីក្រ មានកម្រិតវប្បធម៌ទាប តាមជីវប្រវត្តិរបស់គេ កន្លងមកពុំធ្លាប់ត្រូវបានតុលាការផ្តន្ទាទោសម្តងណាឡើយ គប្បីតុលាការធ្វើការពិចារណាក្នុងការសម្រេចសេចក្តី។

១១-វត្ថុចាប់យកមាន៖

១១.១-ម៉ូតូម៉ាក ហុងដា សេ ១២៥ ពញ្ញ៉ខ្មៅ ពាក់ស្លាកលេខ កំពង់ធំ 1E-7201 គប្បី ប្រគល់ឲ្យម្ចាស់ដើមវិញ។

១១.២-ទូរស័ព្ទដៃ ០១ គ្រឿង ម៉ាក IPhone ៦ ផ្នែស ពណ៌ ស គប្បីប្រគល់ឲ្យម្ចាស់ដើមឈ្មោះ [redacted] **សេងអេង** វិញ ដូចមានកំណត់ហេតុប្រគល់ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២១ របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលអូរបែកក្អម។

១២-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សេងអេង** ពុំទាមទារសំណងការខូចខាតនិងជម្ងឺចិត្ត ដូច្នេះតុលាការមិនពិចារណាអំពីសំណងរដ្ឋប្បវេណីនោះទេ ។

១៣-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ឆ្លងតាមការស្តួរដេញដោលនាពេលសវនាការ មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាប់លើឈ្មោះ [redacted] **សីហា** ភេទប្រុស អាយុ២៨ឆ្នាំ ពីបទ **លួចមានស្ថានទម្ងន់ទោស (ឆក់ទូរស័ព្ទដៃ)** ប្តឹងសុំចៅក្រមផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ គប្បីតុលាការលើកយកការសន្និដ្ឋានរបស់តំណាងអយ្យការមកពិចារណាក្នុងការសម្រេចសេចក្តី។

១៤-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ សុំឱ្យតុលាការកែប្រែបទចោទ លើកូនក្តីខ្លួនពីបទ **លួចមានស្តានទម្ងន់** មកបទ **លួច** វិញ និងសុំឱ្យតុលាការបន្ធូរបន្ថយទោសឱ្យកូនក្តីខ្លួន ពុំមានភស្តុតាងគ្រប់គ្រាន់ អាចឱ្យតុលាការលើកយកមកពិចារណាបានឡើយ។

ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសឈ្មោះ [redacted] **សីហា** ភេទប្រុស អាយុ២៨ ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៣(បី) ឆ្នាំ ។

ពីបទ **លួចមានស្តានទម្ងន់ទោស v (ឆក់ទូរស័ព្ទ)** ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ៣៤៤ ផ្លូវបេតុង ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

២-វត្ថុចាប់យកមាន:

២.១-ម៉ូតូម៉ាកហុងដាសេ១២៥ ពញ៉ខ្មៅ ពាក់ស្លាកលេខ កំពង់ធំ1E-7201 ប្រគល់ឱ្យម្ចាស់ដើម ឈ្មោះ [redacted] **សីហា** វិញ ។

២.២-ទូរស័ព្ទដៃ ០១ គ្រឿង ម៉ាក IPhone ៦ ផ្នើស ពណ៌ ស ប្រគល់ឱ្យម្ចាស់ដើម ឈ្មោះ [redacted] **សេងអេង** វិញ ដូចមានកំណត់ហេតុប្រគល់ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២១ របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលអូរបែកក្អម។

-សាលក្រមនេះជំនុំជម្រះ ជាសាធារណៈ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ ឈ្មោះ [redacted] **សីហា** និងមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ,ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២ ។ ភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

ក្រឡាបញ្ជីសវនាការ ចៅក្រមប្រឹក្សា ចៅក្រមប្រឹក្សា ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

ហត្ថលេខា [redacted]

.....

"បានចំលងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃ សុក្រ ១២កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

Scanned with CamScanner